មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

# សេចក្តីប្រកាសព័ត៌មាន

## មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាផ្តួចផ្តើមធ្វើយុទ្ធនាការដើម្បីប្រារព្ធទិវាសិទ្ធិមនុស្ស អន្តរជាតិសំខាន់ៗ

*រាជធានីភ្នំពេញ ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២២*

នៅថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២២ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា («ម.ស.ម.ក») នឹងផ្តួចផ្តើមធ្វើយុទ្ធនាការ ១៦ ថ្ងៃ ដើម្បីលុបបំបាត់អំពើហិង្សាទាក់ទងនឹងយេនឌ័រ ចាប់ពីថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២២។

ថ្ងៃទី ២៥ ខែវិច្ឆិកា គឺជាទិវាអន្តរជាតិដើម្បីលុបបំបាត់អំពើហិង្សាទៅលើស្ត្រី។ អំពើហិង្សាទៅលើស្ត្រីនៅតែបន្តក្លាយជាការរំលោភបំពានសិទ្ធិមនុស្សដ៏ធ្ងន់ធ្ងរបំផុតមួយនៅលើពិភពលោកនាពេលបច្ចុប្បន្ន ហើយក៏កំពុងសាយភាយនៅកម្ពុជាផងដែរ។ តាមការប៉ាន់ស្មាន មានស្ត្រីកម្ពុជាម្នាក់ក្នុងចំណោមប្រាំនាក់ទទួលរងនូវអំពើហិង្សាពីសំណាក់ដៃគូរបស់ខ្លួន តួលេខនេះគេជឿថាបានកើនឡើងចាប់តាំងពីការរាតត្បាតនៃជំងឺកូវីដ-១៩។ យុទ្ធនាការ ១៦ ថ្ងៃនេះរៀបចំឡើងក្នុងគោលបំណងលើកកម្ពស់ការយល់ដឹងពីសិទ្ធិស្ត្រី និងផលប៉ះពាល់នៃអំពើហិង្សាទាក់ទងនឹងយេនឌ័រក្នុងសហគមន៍ និងអំពាវនាវដល់រាជរដ្ឋាភិបាលកម្ពុជា(«រដ្ឋាភិបាល»)ចាត់វិធានការដាក់លាក់ជាបន្ទាន់ដើម្បីបញ្ចប់អំពើហិង្សាទាក់ទងនឹងយេនឌ័រ និងលើកកម្ពស់សមភាពយេនឌ័រនៅកម្ពុជា។

យុទ្ធនាការនេះនឹងប្រព្រឹត្តទៅរហូតដល់ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២២ ដែលជាទិវាសំខាន់នៃការប្រារព្ធខួបនៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សដែលជាឯកសារសំខាន់នាំមកនូវការវិវឌ្ឍផ្នែកសិទ្ធិមនុស្ស ដែលជួយពង្រឹងក្របខ័ណ្ឌសិទ្ធិមនុស្ស និងមានចែងសិទ្ធិមនុស្សជាមូលដ្ឋានសំខាន់ៗសម្រាប់មនុស្សគ្រប់រូប។ ប្រធានបទសម្រាប់ទិវាសិទ្ធិមនុស្សនៅឆ្នាំ២០២២នេះគឺ «**ក្តីសង្ឃឹមជីវិតរស់នៅក្នុងភាពថ្លៃថ្នូរ មានសេរីភាព សមភាព និងយុត្តិធម៌**»។

ក្នុងអំឡុងពេលនេះ ម.ស.ម.ក ក៏នឹងប្រារព្ធទិវាសិទ្ធិមនុស្សសំខាន់ៗមួយចំនួនទៀតដែលមាននៅលើប្រតិទិនសិទ្ធិមនុស្សផងដែរ ដូចជា ទិវាអ្នកការពារសិទ្ធិមនុស្សជាស្ត្រី នៅថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២២ និងទិវាអ្នកការពារសិទ្ធិមនុស្សអន្តរជាតិនៅថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០២២ ដែលជាទិវាសំខាន់បង្ហាញនូវការប្តេជ្ញាចិត្ត និងឆន្ទៈរបស់អ្នកការពារសិទ្ធិមនុស្សក្នុងការតស៊ូមតិ ការអប់រំ និងការលើកកម្ពស់ការយល់ដឹងពីសិទ្ធិមនុស្សក្នុងសហគមន៍របស់ខ្លួន។

សង្ខេបមក ទិវាសំខាន់ៗទាំងនេះគឺជាកាលានុវត្តភាពសម្រាប់ដៃគូពាក់ព័ន្ធ ជាពិសេស រដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលបញ្ជាក់ការប្តេជ្ញាចិត្តរបស់ខ្លួនក្នុងការការពារ និងលើកកម្ពស់សិទ្ធិមនុស្ស។

ក្នុងយុទ្ធនាការនេះ ម.ស.ម.ក នឹងអនុវត្តសកម្មភាពតាមលំដាប់លំដោយ ដូចមានបញ្ជាក់ខាងក្រោម៖

- **ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២២៖** ក្នុងឱកាសនៃទិវាអន្តរជាតិដើម្បីលុបបំបាត់អំពើហិង្សាលើស្ត្រី ម.ស.ម.ក នឹងចេញផ្សាយកាលប្បវត្តិព្រឹត្តិការណ៍កូដកម្មណាហ្គាវើលដ៍លើកទី៣ ផ្តោតលើ

ករណីរំលោភបំពានប្រព្រឹត្តទៅលើកូដករជាស្ត្រី។

- **ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ ២០២២៖** ម.ស.ម.ក នឹងចេញសេចក្តីប្រកាសអញ្ជើញសាធារណជនចូលរួមឆ្លើយសំណួរពាក់ព័ន្ធនឹងទិវាសិទ្ធិមនុស្សតាមរយៈទំព័រហ្វេសប៊ុករបស់ ម.ស.ម.ក។
- **ថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ២០២២៖** ក្នុងឱកាសទិវាអ្នកការពារសិទ្ធិមនុស្សជាស្ត្រី ម.ស.ម.ក នឹងចេញផ្សាយខិត្តប័ណ្ណព័ត៌មានលើកឡើងអំពីវឌ្ឍនភាពនៃការអនុវត្តសាសន៍យូភីអជុំទី៣ ទាក់ទងនឹងសមភាពយេនឌ័រ និងសិទ្ធិស្ត្រី។
- **ថ្ងៃទី ០៧ ខែធ្នូ ឆ្នាំ ២០២២៖** ម.ស.ម.ក នឹងប្រកាសលទ្ធផលនៃអ្នកចូលរួមឆ្លើយសំណួរអនឡាញទាក់ទងនឹងទិវាសិទ្ធិមនុស្សដែលត្រូវទទួលរង្វាន់នៅលើទំព័រហ្វេសប៊ុករបស់ ម.ស.ម.ក។
- **ថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២២៖** ម.ស.ម.ក នឹងរៀបចំកម្មវិធីប្រកួតបាល់ទាត់ដណ្តើមជ័យលាភីសិទ្ធិមនុស្សដើម្បីចូលរួមប្រារព្ធទិវាសិទ្ធិមនុស្សអន្តរជាតិ។
- **ថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០២២៖** ម.ស.ម.ក នឹងចូលរួមកម្មវិធីរៀបចំដោយការិយាល័យនៃឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា ដើម្បីប្រារព្ធទិវាអ្នកការពារសិទ្ធិមនុស្សអន្តរជាតិ និងទិវាសិទ្ធិមនុស្សអន្តរជាតិ។
- **ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២២៖** ដើម្បីចូលរួមប្រារព្ធទិវាសិទ្ធិមនុស្សអន្តរជាតិ និងបិទបញ្ចប់យុទ្ធនាការនេះ ម.ស.ម.ក នឹងចេញផ្សាយកាលប្បវត្តិសិទ្ធិមនុស្សឆ្នាំ២០២២ ព្រមទាំងមានបង្ហាញទិដ្ឋភាពសំខាន់ៗមួយចំនួនតាមលំដាប់នៃខែនីមួយៗផងដែរ។

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងលោក សួន យុធ្យា នាយកតស៊ូមតិ ម.ស.ម.ក តាមរយៈទូរស័ព្ទ: + ៨៥៥ (០) ៨៨ ៨១៤ ២៧៨៣ ឬ អ៊ីម៉ែល:**yuthyia@cchrcambodia.org **ឬ លោក លឹម បូរិន អ្នកសម្របសម្រួលគម្រោងនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ/ការបង្ហាញទំនោរយេនឌ័រ និងលក្ខណៈភេទ តាមរយៈទូរស័ព្ទ: + ៨៥៥ (០) ១២ ៩០៤ ២៦៦ ឬ អ៊ីម៉ែល:** borin.lim@cchrcambodia.org**។**

**- ចប់ -**

**<u>បណ្ណាធិការ៖</u>**

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា («ម.ស.ម.ក») ជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ មិនចូលបក្សសម្ព័ន្ធដែលធ្វើការដើម្បីលើកកម្ពស់និងការពារសិទ្ធិមនុស្ស ជាពិសេសសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ លទ្ធិប្រជាធិបតេយ្យ និងនីតិរដ្ឋនៅព្រះរាជាណាចក្រកម្ពុជា។

ម.ស.ម.ក ជាសមាជិកនៃដៃគូសន្ទនាអន្តរជាតិដើម្បីសេរីភាពបញ្ចេញមតិ (IFEX) បណ្តាញសកលដើម្បីសេរីភាពខាងការបញ្ចេញមតិ និងសម្ព័ន្ធពិភពលោកដើម្បីការចូលរួមពលរដ្ឋ (CIVICUS)។ ម.ស.ម.ក ក៏ជាសមាជិកនៃអង្គការពិភពលោកប្រឆាំងនឹងទារុណកម្ម (OMCT) ជាសមាជិក OECD-Watch ជាសមាជិកនៃបណ្តាញប្រឆាំងទារុណកម្ម អេស អូ អេស និងសម្ព័ន្ធសារព័ត៌មានអាស៊ីអាគ្នេយ៍ (SEAPA) ផងដែរ។

គេហទំព័រអំពីសិទ្ធិមនុស្សកម្ពុជា www.sithi.org ជាជ័យលាភីដែលបានទទួលពានរង្វាន់មូលនិធិនៃការបង្កើតសារព័ត៌មានថ្មីប្រចាំឆ្នាំ២០១១ស្ថិតក្នុងប្រភេទ «សិទ្ធិ និងសេរីភាព» និងជាជ័យលាភីទទួលពានរង្វាន់ក្នុងឆ្នាំ២០១៣ ផ្នែកទំនាក់ទំនងដើម្បីផ្លាស់ប្តូរសង្គមមកពីមជ្ឈមណ្ឌលសម្រាប់ទំនាក់ទំនង និងការផ្លាស់ប្តូរសង្គមនៅសាកលវិទ្យាល័យឃ្វីនស្លែន ក្នុងទីក្រុងប្រ៊ីសបេន ប្រទេសអូស្ត្រាលី